# មន្ទីរកសិកម្មខេត្តកណ្ដាល

## ជីគីមី និងការប្រើប្រាស់




អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)


---


ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

ឆ្នាំ ២០១០

education for development


## ជីគីមី និងការប្រើប្រាស់

ជីគីមី គឺជាសារធាតុចិញ្ចឹមទោល ឬសមាសដែលគេប្រើ ដើម្បីបង្កើនការលូតលាស់ទិន្នផល និងគុណភាពរបស់ដំណាំ។ ជីគីមី គឺជាប្រភេទជី ដែលសំយោគ ឬផលិតចេញពីរោងចក្រ។

- ជីទោល ជាប្រភេទជីអសរីរាង្គដែលមានធាតុសកម្មតែមួយប្រភេទ។

<u>ឧទាហរណ៍</u> ជីអ៊ុយរ៉េ (៤៦-00-00)

ជីប៉ូតាស្យូមក្លរួ (00-00-៦0)

- ជីសមាសជាប្រភេទជីអសរីរាង្គដែលមានធាតុសកម្ម ចាប់ពី ២ ប្រភេទឡើងទៅ។

<u>ឧទាហរណ៍</u> ជីដេអាប៉េ (១៨-៤៦-00)

ជីកែង-កែង (១៥-១៥-១៥)

*របៀបគណនាជីគីមីសម្រាប់ប្រើប្រាស់ក្នុងដី ១ ហិចតា

| បរិមាណជីប្រើ = | ធាតុចិញ្ចឹមតាមបទដ្ឋាន x ១00 |
|---|---|
| | ធាតុចិញ្ចឹមក្នុងជី |

**<u>ឧទាហរណ៍ទី</u> ១** រូបមន្តក្រុមដីព្រៃខ្មែរដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $\mathbf{N_{៥២}}$ $\mathbf{P_{១៥}}$ $\mathbf{K_{២០}}$ (គក្រ/ហិចតា។

យើងប្រើជីអ៊ុយរ៉េ (N = ៤៦%) ជីដេអាប៉េ (N=១៨%) ($P_{២}O_{៥}$=៤៦%) និង ជីប៉ូតាស្យូមក្លរួ ($K_{២}O$=៦០%)។

<u>ជាដំបូងយើងត្រូវគណនារក $\mathbf{K_{២០}}$</u> (គក្រ) ពីជីប៉ូតាស្យូមក្លរួ

$$K_{20}\ (គក្រ) = \frac{២00 \times ១00}{៦0} = ៣៣,៣៣\ គក្រ$$

<u>បន្ទាប់មកយើងគណនារក $\mathbf{P_{១៥}}$</u> (គក្រ) <u>ពីជីដេអាប៉េ</u>

$$P_{15}\ (គក្រ) = \frac{១៥ \times ១00}{៤៦} = ៣២,៦0គក្រ$$

ក្នុងជីដេអាប៉េ ១00គក្រ មានធាតុ N = ១៨គក្រ ដូច្នេះ

ក្នុងជីដេអាប៉េ ៣២,៦0គក្រ មានធាតុ Nគក្រ

$$N\ (គក្រ) = \frac{១៨ \times ៣២,៦0}{១000} = ៥,៨៦គក្រ\ (=៦\ គក្រ)$$

នាំអោយយើងនៅសល់

| | | | | |
|---|---|---|---|---|
| | $N_{52}$ | $P_{15}$ | $K_{20}$ | |
| - | $N_{6}$ | $P_{15}$ | $K_{20}$ | |
| | $N_{46}$ | $P_{0}$ | $K_{0}$ | ត្រូវគណនា |

<u>ចុងក្រោយយើងគណនារក $\mathbf{N_{៤៦}}$ (គក្រ) ពីជីអ៊ុយរ៉េ</u>

$$N_{46}\ (គក្រ) = \frac{៤៦ \times ១00}{៤៦} = ១00គក្រ$$

**ជាចំលើយរូបមន្តដីព្រៃខ្មែរ $\mathbf{N_{៥២}}$ $\mathbf{P_{១៥}}$ $\mathbf{K_{២០}}$** (គក្រ/ហត)

យើងប្រើជីៈ
- ប៉ូតាស្យូមក្លរួ (គជល) = **<u>៣៣,៣៣ គក្រ</u>**
- ដេអាប៉េ (AB) = **<u>៣២,៦0 គក្រ</u>**
- អ៊ុយរ៉េ (Ure) = **<u>១00 គក្រ</u>**

**ឧទាហរណ៍ទី ២** រូបមន្តក្រុមដីប្រទះឡាងដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{60}$ $P_{29}$ $K_{30}$ (គក្រ/ហិចតា)។ ជាចំលើយគឺយើងប្រើជីៈ

- ជីប៉ូតាស្យូមក្លរួ (គជល) = <u>៥0 គក្រ</u>
- ជីដេអាប៉េ ((AB) = <u>៦៣ គក្រ</u>
- ជីអ៊ុយរ៉េ (Ure) = <u>១0៦,៥0 គក្រ</u>

**ឧទាហរណ៍ទី ៣** រូបមន្តក្រុមដីបាកានដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{70}$ $P_{30}$ $K_{15}$ (គក្រ/ហិចតា)។ ជាចំលើយគឺយើងប្រើជីៈ

-ជីប៉ូតាស្យូមក្លរួ (គជល) = <u>២៥ គក្រ</u>

-ជីដេអាប៉េ ((AB) = **១៥ គក្រ**

-ជីអ៊ុយរ៉េ (Ure) = **១២៧ គក្រ**

**ឧទាហរណ៍ទី ៤** រូបមន្តក្រុមដីក្បាលពោធិដែលប្រើពូជស្រូវទំនើបនិងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{120}$ $P_{34}$ $K_0$ (គក្រ/ហិចតា) ។ ជាចំលើយគឺយើងប្រើជី:

-ជីដេអាប៉េ (AB) = **៧៤ គក្រ**

-ជីអ៊ុយរ៉េ (Ure) = **២៣២ គក្រ**

១-ដើម្បីប្រើប្រាស់ជីគីមីឱ្យមានប្រសិទ្ធិភាពយើងត្រូវគិតពី:

-ដី តើដីនោះប្រភេទដីអ្វី

-ពូជ តើយើងប្រើពូជក្នុងស្រុក (ពូជប្រពៃណី ) ឬពូជទំនើប (ពូជបង្កាត់ )

-រដូវកាលដាំដុះ តើយើងធ្វើការដាំដុះនៅរដូវណា (រដូវប្រាំង ឬ រដូវវស្សា )

-ទឹក ស្រែមានទឹក ឬ ស្រែគ្មានទឹក

-ស្មៅ មុនពេលបាចជីត្រូវបោចស្មៅឱ្យអស់ពីក្នុងស្រែ

-ដំណាក់កាលលូតលាស់ តើដល់ដំណាក់កាលណាហើយ

-កំរិតប្រើប្រាស់ជី អាស្រ័យទៅតាមក្រុមដី (តាមសៀវភៅដីសំរាប់ផលិតកម្មស្រូវនៅកម្ពុជា (CARDI) ។

**២-តួនាទីរបស់ធាតុ <u>N-P-K</u>**

-N ជួយស្លឹកអោយមានពណ៌បៃតងក្រម៉ៅ ជំរុញការលូតលាស់ដើមបែកគុម្ពល្អ

-P ជួយប្រព័ន្ធដល់ឫស ជំរុញឱ្យឆាប់ចេញផ្កា និងមានភាពទុំល្អ បង្កើនគុណភាពគ្រាប់

-K ជួយឱ្យដើមស្រូវមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ ជំរុញការបែកគុម្ព បង្កើនទំហំ និងទំងន់គ្រាប់ ។

**៣-ការបាចជីលើស្រែសន្ទូង និងពង្រួស**

- ការបាចជីលើស្រែសន្ទូងចែកចេញ ៣ លើកគឺ:

- លើកទី១ បាចទ្រាប់បាត ប្រើជីធម្មជាតិ ១០០% ជីដេអាប៉េ ១០០% ជីអ៊ុយរ៉េ ៣០%
- លើកទី២ បាចបំប៉នក្រោយពីស្ទូង ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយស្ទូង ១០-១៥ថ្ងៃ
  - ស្រូវកណ្តាល ក្រោយស្ទូង ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយស្ទូង ៣០-៣៥ថ្ងៃ
- លើកទី៣ បាចបំប៉នពេលស្រូវចាប់ផ្តើមកំណកំណើតកួរ ប្រើជីអ៊ុយរ៉េ ៤០%

- ការបាចជីលើស្រែពង្រួសចែកចេញ ៤ លើកគឺ:

- លើកទី១ បាចទ្រាប់បាត (ពេលភ្ជួរ-រាស់ព្រួស) ប្រើជីធម្មជាតិ ១០០% ជីដេអាប៉េ ១០០%
- លើកទី២ បាចបំប៉នក្រោយព្រួស, ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយព្រួស ១០-១៥ថ្ងៃ
  - ស្រូវកណ្តាល ក្រោយព្រួស ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយព្រួស ២៥-៣០ថ្ងៃ
- លើកទី៣ បាចក្រោយបំប៉នលើកទី ២ ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយបំប៉នទីពីរ ១៥-២០ថ្ងៃ
  - ស្រូវកណ្តាល ក្រោយបំប៉នទីពីរ ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយបំប៉នទីពីរ ២៥-៣០ថ្ងៃ
- លើកទី៤ បាចបំប៉នពេលស្រូវចាប់ផ្តើមកំណកំណើតកួរ ប្រើជីអ៊ុយរ៉េ ៤០% ។

**៤-ពេលវេលាបាចជី**

-បាចជីពេលព្រឹក ឬពេលល្ងាច អាស្រ័យតាមអាកាសធាតុ

-គួរបាចជីនៅពេលស្លឹកស្រូវស្ងួត ។

**៥-កត្តាគួរជៀសវាង**

-ហាមបាចជីក្រោយពេលភ្លៀង ឬពេលស្លឹកស្រូវនៅសើម

- មុនពេលភ្លៀងធ្លាក់មិនត្រូវបាចជីឡើយ

-ហាមបាចជីលើស្រែមានទឹកច្រើនពេក ឬគ្មានទឹក

-ហាមបាចជីពេលស្រូវកំពុងមានជំងឺ ឬសត្វល្អិតបំផ្លាញ

-ហាមបាចជីលើស្រែដែលមានស្មៅដុះច្រើន

-ហាមបាចជីអោយលើសពីសេចក្តីត្រូវការរបស់ស្រូវ... ។

